សាលាឧទ្ធរណ៍ភ្នំពេញ

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ៣៣៣

ចុះថ្ងៃទី ២៥ _០៥ _១០

សាលដីកា

លេខ : ០៤ "ក្រVI អ"

ចុះថ្ងៃទី ២៧_០១_២០១១

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីដែលប្រកាសឱ្យប្រើ តាមក្រឹត្យលេខ ០៦ក្រ ចុះថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍ នាថ្ងៃទី ០៦ ខែមករា ឆ្នាំ២០១១ ដោយមានសមាសភាពដូចខាងក្រោម:

**ក្រុមប្រឹក្សាជំនុំជម្រះ**

- លោក [redacted] ជាប្រធាន
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃសំណុំរឿងព្រហ្មទណ្ឌលេខ ៣៣៣ ចុះថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០១០ រវាង:

- ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ ៣៨ឆ្នាំ ជាតិខ្មែរ កើតនៅភូមិរលួង ឃុំរលួង ឃុំគោករការ ស្រុកដង្កោ ខេត្តកណ្តាល ទីលំនៅពេលចាប់ខ្លួនភូមិរលួង សង្កាត់គោករការ ខណ្ឌដង្កោ រាជធានីភ្នំពេញ មុខរបរពាណិជ្ជករ ឪពុកឈ្មោះ [redacted] ស៊ ម្តាយឈ្មោះ [redacted] រ៉ ប្រពន្ធឈ្មោះ [redacted] កូនគ្មាន ឃាត់ខ្លួនថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ២០០៨ ឃុំខ្លួនថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ២០០៨។

មានលោកស្រី [redacted] ជាមេធាវីការពារ។



Scanned by CamScanner

**<u>ជាប់ចោទពីបទ:</u>** ផ្តល់សក្ខីភាពក្លែង និងក្លែងលិខិតឯកជន ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ០៤ ខែតុលា ឆ្នាំ២០០៤. ថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ១៩៩៣ និងកាលពីថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៩៣ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៥០. ៥៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទប្រុស អាយុ ៥៣ឆ្នាំ ទីលំនៅសព្វថ្ងៃផ្ទះលេខ ២៤៥ ផ្លូវ ១០១៩ ភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

<u>ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ</u>

កាលពីថ្ងៃទី ០៤ ខែតុលា ឆ្នាំ២០០៤. ថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ១៩៩៣ និងកាលពីថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៩៣ បានធ្វើសកម្មភាពជាមួយតួកនក្លែងលិខិតឯកជន និងផ្តល់សក្ខីភាពក្លែងក្នុងគោលបំណងបន្លំឈ្មោះស្នាមមេដៃរបស់ឈ្មោះ [redacted] ដើម្បីរំលោភយកដីនៅចំណុចភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ពីម្ចាស់កម្មសិទ្ធិខាងលើ ។

**បានឃើញ** សាលក្រមព្រហ្មទណ្ឌលេខ ៤៨ ឆ ចុះថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:

១- ផ្តន្ទាទោសឈ្មោះ [redacted] ភេទប្រុស អាយុ ៣៨ឆ្នាំ ជាតិខ្មែរ កើតនៅភូមិអណ្តូង ផ្លូវលំ ឃុំគោករការ ស្រុកដង្កោ ខេត្តកណ្តាល ទីលំនៅពេលចាប់ខ្លួនភូមិអណ្តូង សង្កាត់គោករការ ខណ្ឌដង្កោ រាជធានីភ្នំពេញ មុខរបរពាណិជ្ជករ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ´រ´ ប្រពន្ធឈ្មោះ [redacted] ទគ្មាន ទោសពីមុនមាន ។

ដាក់ពន្ធនាគារសរុបកំណត់ ៤ឆ្នាំ ( បួនឆ្នាំ) តិតបន្តពីសាលក្រមមុន ពិន័យជាប្រាក់ចំនួន ៤.០០០.០០០ រៀល ( បួនលានរៀល) សម្រាប់ដាក់ចូលក្នុងថវិការដ្ឋ ពីបទ ផ្តល់សក្ខីភាពក្លែង និងក្លែងលិខិតឯកជន ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០០៤. កាលពីថ្ងៃទី ១៩ ខែឧសភា ឆ្នាំ២០០៤. ថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ១៩៩៣ និងកាលពីថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៩៣ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៥០. ៥៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២- បង្គាប់ឱ្យឈ្មោះ [redacted] សងថ្លៃការខូចខាត និងជម្ងឺចិត្តចំនួន ៤០.០០០.០០០រៀល ( សែសិបលានរៀល) ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ដែលមានលោកមេធាវី [redacted] ជាតំណាង ។ សុំលើសពីនេះត្រូវច្រានចោល ។

៣- បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ ២៧៨ ចុះថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ២០០៧ ទៅព្រះរាជអាជ្ញាអមសាលាដំបូងរាជធានីភ្នំពេញ ដើម្បីបើកការស៊ើបសួរលើតួកន និងចាត់ការតាមនីតិវិធី ។



Scanned by CamScanner

៤- សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០០៩ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ២០០៩ ចំពោះមុខជនជាប់ចោ[redacted]មធាវីការពារជនជាប់ចោទ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

- បានឃើញ ពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០០៩ របស់ឈ្មោ[redacted]ឧទ្ធរណ៍ នឹងសាលក្រមព្រហ្មទណ្ឌលេខ ៤៨ ក ចុះថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ។

- បានឃើញរបាយការណ៍រឿងព្រហ្មទណ្ឌរបស់ចៅក្រមរបាយការណ៍ សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ។

<u>**នាពេលសវនាការ**</u>

- ជនជាប់ចោទឈ្មោះ [redacted] (វត្តមាន)
- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] (អវត្តមាន)
- លោកស្រី[redacted]មេធាវីការពារជនជាប់ចោទ(វត្តមាន)

ជនជាប់ចោទឈ្មោះ [redacted] ឆ្លើយថាៈ ខ្លួនប្តឹងឧទ្ធរណ៍មកដោយសារសាលាដំបូងរាជធានីភ្នំពេញ ផ្តន្ទាទោសខ្លួនច្រើនពេក ហើយការទិញដី និងលុយកាក់ទិញដី គឺតាមរយៈឈ្មោ[redacted] ហើយខ្លួនពុំដែលប្រគល់លុយឱ្យទៅម្ចាស់ដីផ្ទាល់ទេ ។ សំណូមពរ សុំឱ្យតុលាការមេត្តាបន្ធូរបន្ថយទោសឱ្យខ្លួនផង ។

តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋានថាៈ សំណូមពរ សុំឱ្យក្រុមប្រឹក្សាតម្កល់សាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល ។

លោកស្រី[redacted]ជាមេធាវីការពារជនជាប់ចោទធ្វើការការពារថាៈ សំណូមពរ សុំឱ្យក្រុមប្រឹក្សាមេត្តាពិចារណាស្រូបទោសឱ្យកូនក្តីខ្លួនដោយក្តីអនុគ្រោះ ។

- ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ
- ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអបាអយ្យការអមសាលាឧទ្ធរណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ
- ក្រោយពីបានពិនិត្យពិភាក្សានិងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

**សភាព្រហ្មទណ្ឌ យល់ឃើញថា**

១- បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០០៩ របស់ឈ្មោះ[redacted]ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន យោងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២- តាមអង្គហេតុបញ្ជាក់ថា ជនជាប់ចោទឈ្មោះ [redacted] ពិតជាបានផ្ដល់សក្ខីភាពក្លែងក្លាយប្រាកដមែន ពីព្រោះ កិច្ចសន្យា ចុះថ្ងៃទី ០៤ ខែតុលា ឆ្នាំ២០០៤ ថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ១៩៩៣ និងថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៩៣ ថា ខ្លួនបានបន្លំស្នាមមេដៃរបស់ឈ្មោះ [redacted] ដើម្បីរំលោភយកដីលើឈ្មោះខាងលើយកទៅ លក់ឱ្យអ្នកផ្សេងទៀត ។

៣- តាមចម្លើយឈ្មោ[redacted]ាដើមបណ្ដឹងរដ្ឋប្បវេណីបានឆ្លើយថា ខ្លួនពុំដែលបានចុះកិច្ចសន្យា ឬផ្តិតមេដៃកិច្ចសន្យាទិញ និងលក់ដី ចុះថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ១៩៩៣ និងលិខិតប្រគល់ប្រាក់ផ្ដាច់ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៩៣ ជាមួយឈ្មោះ[redacted] ទេ ហើយម្យ៉ាងទៀត ខ្លួនក៏មិនស្គាល់ឈ្មោះ [redacted]ដែរ នេះបញ្ជាក់ឱ្យ ឃើញថា ឈ្មោ[redacted]ាបានផ្ដល់សក្ខីភាពក្លែងប្រាកដមែន ។

៤- កិច្ចសន្យាទិញ និងលក់ ចុះថ្ងៃទី ០៤ ខែតុលា ឆ្នាំ២០០៤ ថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ១៩៩៣ និងថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៩៣ បញ្ជាក់ថា ឈ្មោ[redacted]ានលក់ និងទទួលប្រាក់ពីឈ្មោះ[redacted]តែតាមការពិតឈ្មោះ [redacted]នធ្វើឯកសារក្លែងតាំងពីដើមរហូតដល់ចប់ ។

៥- តាមការយល់ឃើញខាងលើ និងភស្តុតាងក្នុងសំណុំរឿងបញ្ជាក់ថា មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted]ពីបទ ផ្ដល់សក្ខីភាពក្លែង និងក្លែងលិខិតឯកជន ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ០៤ ខែតុលា ឆ្នាំ២០០៤. ថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ១៩៩៣ និងថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៩៣ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្ដន្ទាទោសតាមមាត្រា ៥០. ៥៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៦- រឿងក្ដីនេះត្រូវបានសាលាដំបូងរាជធានីភ្នំពេញ ធ្វើការអង្កេត និងលើកយកសំអាងហេតុមកបញ្ជាក់ត្រឹមត្រូវតាមច្បាប់ ហើយសាលាឧទ្ធរណ៍ឯកភាពលើសំអាងហេតុនោះ ដូចនេះ សាលាឧទ្ធរណ៍មិនចាំបាច់លើកយកសំអាងហេតុនេះមកបញ្ជាក់ជាថ្មីទៀតទេ ។

៧- សាលក្រមព្រហ្មទណ្ឌលេខ ៤៨ ឆ ចុះថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល ។

## <u>ហេតុដូច្នេះ</u> <u>សភាព្រហ្មទណ្ឌ</u>

## <u>វិនិច្ឆ័យសេចក្ដី</u>

១- ទទួលបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted]កជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយថ្មុយនឹងគតិច្បាប់ ។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៤៨ ឆ ចុះថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការពេញទាំងមូល ។

៣- បន្តការឃុំខ្លួនជនជាប់ចោទឈ្មោះ[redacted]តាមនីតិវិធីច្បាប់ ។

30/1

៤- សាលដីកានេះជំនុំជម្រះនៅថ្ងៃទី ០៦ ខែមករា ឆ្នាំ២០១១ ចំពោះមុខមេធាវីការពារជនជាប់ចោទ និងជនជាប់ចោទ និងប្រកាសជាសាធារណៈនៅថ្ងៃទី ២៧ ខែមករា ឆ្នាំ២០១១ កំបាំងមុខមេធាវីការពារជនជាប់ចោទ និងជនជាប់ចោទ ។

បើកសិទ្ធិឱ្យប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

ក្រឡាបញ្ជី
ហត្ថលេខា: [redacted]

ចៅក្រមប្រឹក្សា
ហត្ថលេខា: [redacted]

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
ហត្ថលេខ[redacted]

---

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
សាលាឧទ្ធរណ៍ ថ្ងៃទី 09 ខែ 02 ឆ្នាំ២០១១
ក្រឡាបញ្ជី
[redacted]

បានឃើញ
ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
[redacted]



Scanned by CamScanner